

## ការចិញ្ចឹមជីវិតដោយខ្លួនឯង - យុទ្ធសាស្ត្រផ្តោតរបស់អាយស៊ីស៊ី

*"ពួកយើងបានធ្វើការនៅប្រទេសថៃជាងមួយឆ្នាំហើយ ប៉ុន្តែពួកយើងគ្មានបាននៅសល់អីសោះ"។ កូនស្រីម្នាក់បានទូរស័ព្ទមកកាន់ម្តាយរបស់នាង ខណៈពេលដែលនាងនិងប្តី កំពុងតែធ្វើការជាពលករនៅប្រទេសថៃ។ ពួកគេបានធ្វើការចំណាកស្រុកទៅប្រទេសថៃ ដោយសង្ឃឹមថានឹងទទួលបានប្រាក់ចំណូលច្រើន ដើម្បីធ្វើការសងបំណុល និងដើម្បីផ្គត់ផ្គង់ដល់កូនប្រុសរបស់ពួកគេ ដែលកំពុងតែរស់នៅជាមួយនឹងជីដូននៅក្នុងប្រទេសកម្ពុជា។*

នេះគឺជារឿងរ៉ាវផ្ទាល់ខ្លួនមួយ ដែលត្រូវបានចែកចាយដោយស្ត្រីមេម៉ាយម្នាក់នៅក្នុងខេត្តព្រៃវែងដែលកូនស្រី និងកូនប្រសាររបស់គាត់បានធ្វើការចំណាកស្រុកទៅប្រទេសថៃ។ នៅពេលដែលកូនស្រីនិងកូនប្រសារ បានទៅដល់ប្រទេសថៃភ្លាម ពួកគេគិតថាអាចរកចំណូលបានច្រើនជាងនៅប្រទេសកម្ពុជា។ ដោយបានការងារធ្វើត្រឹមជាអ្នកថែរក្សាចម្ការ និងជាអ្នកបាញ់ថ្នាំគីមីសម្លាប់សត្វល្អិត ធ្វើឲ្យកូនស្រីរបស់គាត់រកប្រាក់ចំណូលបានតែ ៦ដុល្លារក្នុងមួយថ្ងៃតែប៉ុណ្ណោះ ខណៈពេលដែលកូនប្រសាររបស់គាត់រកបាន ៧.៥ដុល្លារប៉ុណ្ណោះក្នុងមួយថ្ងៃ។ ពួកគេមិនបានទទួលនូវអត្ថប្រយោជន៍ការងារ ដូចជាអាហារប្រចាំថ្ងៃ ធានារ៉ាប់រងសុខភាព ឬអត្ថប្រយោជន៍ការងារផ្សេងទៀតនោះឡើយ ពីថៅកែជនជាតិថៃរបស់ពួកគេ។ ក្នុងមួយខែៗ ពួកគេស្ទើរតែគ្មានប្រាក់គ្រប់គ្រាន់ ដើម្បីផ្ញើមកសងបំណុល។ មុនកើតឡើងរឿងនេះ គ្រួសារកូនស្រីគាត់ បានធ្លាក់ចូលទៅក្នុងបំណុលយ៉ាងធ្ងន់ធ្ងរ ដែលនេះជាហេតុបង្ខំឲ្យកូនស្រីនិងកូនប្រសាររបស់គាត់ ធ្វើការចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសថៃដោយមិនបានដឹងច្បាស់ អំពីហានិភ័យនៃការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការធ្វើចំណាកស្រុកខុសច្បាប់។ ផ្ទុយទៅវិញ ពួកគេបានធ្វើ តាមអ្នកដទៃទៀតនៅក្នុងស្រុក ដោយធ្វើការចំណាកស្រុកទាំងខ្វះការ ពិចារណា ដោយគ្មានសុវត្ថិភាព និងខ្វះព័ត៌មានច្បាស់លាស់អំពីការងារ ដែលត្រូវធ្វើនៅទីនោះ។

ក្រោយមកស្ត្រីមេម៉ាយរូបនេះ បានក្លាយទៅជាសមាជិកនៃក្រុមជួយខ្លួនឯង (ក.ជ.ខ) នៅក្នុងភូមិរបស់គាត់ ហើយគាត់បានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនដូចជា ការជួញដូរកម្លាំងពលកម្ម ការធ្វើចំណាកស្រុកខុសច្បាប់ ការត្រិះរិះពិចារណា និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដែលវគ្គបណ្តុះបណ្តាលទាំងអស់នេះបានធ្វើឡើងដោយក្រុមការងារនៃគម្រោងកាត់បន្ថយហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់ (ក.ប.ធ.ច.ស.ខ.ច) របស់អង្គការអាយស៊ីស៊ី។ បន្ទាប់មកគាត់ក៏បានយល់ដឹងពីសារៈសំខាន់នៃវគ្គបណ្តុះបណ្តាលទាំងអស់នេះ ជាពិសេសនៅក្នុងខណៈពេលដែលកូនស្រី និងកូនប្រសាររបស់គាត់កំពុងធ្វើជាពលករនៅប្រទេសថៃ។ ថ្ងៃមួយ កូនស្រីរបស់គាត់បានទូរស័ព្ទមកគាត់ រៀបរាប់អំពីស្ថានភាពការងារដែលមិនសូវល្អនៅក្នុងប្រទេសថៃ។ ដោយសារតែចំណេះដឹងដែលគាត់ទទួលបានពីការបណ្តុះបណ្តាលផ្សេងៗ តាមរយៈគម្រោង ក.ប.ធ.ច.ស.ខ.ច គាត់បានប្រាប់ឲ្យកូនស្រីនិងកូនប្រសាររបស់គាត់ត្រលប់មក ប្រទេសកម្ពុជាវិញ ដោយសារតែឥឡូវនេះប្រទេសកម្ពុជាមានឱកាសការងារ ច្រើនណាស់ ដែលមានប្រាក់ខែស្រដៀងគ្នាទៅនឹងប្រទេសថៃ។ ការចេះផ្តល់ដំបូន្មានបែបនេះ គឺដោយសារតែការចេះវិភាគ និងប្រៀបធៀបរវាងផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាននៃការធ្វើចំណាកស្រុក និងក្រៅប្រទេស តាមរយៈវគ្គបណ្តុះបណ្តាលរបស់គម្រោង ក.ប.ធ.ច.ស.ខ.ច។

កូនស្រីនិងកូនប្រសាររបស់គាត់បានសម្រេចចិត្តត្រលប់មកផ្ទះវិញនៅខែមិថុនា ឆ្នាំ២០១៨។ កូនស្រីរបស់គាត់បានចាប់ផ្តើមធ្វើការនៅរោងចក្រកាត់ដេរមួយ ហើយកូនប្រសាររបស់គាត់បានចាប់ផ្តើមធ្វើការជាអ្នកបើកបរនៅទីក្រុងភ្នំពេញ។ ពួកគេក៏បានយកកូនមករស់នៅភ្នំពេញផងដែរ ដើម្បីឲ្យបានចូលរៀន។ បច្ចុប្បន្ននេះជីវភាពរស់នៅរបស់ពួកគេបានមានការប្រសើរឡើង ហើយពួកគេអាចមានលទ្ធភាពបង់ថ្លៃការសិក្សារបស់កូនបាន ក៏ដូចជាមានលទ្ធភាពក្នុងការសងបំណុលរបស់ពួកគេផងដែរ។ កូនស្រីនិងកូនប្រសាររបស់គាត់មានការសោកស្តាយខ្លាំងណាស់ ចំពោះបទពិសោធន៍នៃការធ្វើចំណាកស្រុកទៅប្រទេសថៃ ដើម្បីស្វែងរកការងារល្អធ្វើ ដោយសារតែមិនដឹងថាបច្ចុប្បន្ននេះប្រទេសកម្ពុជាមានឱកាសការងារច្រើនណាស់ បើប្រៀបធៀបទៅនឹងអតីតកាល។

ស្ត្រីមេម៉ាយម្នាក់នេះបានបន្តចូលរួមនៅគ្រប់សកម្មភាពរបស់ គម្រោង ក.ប.ធ.ច.ស.ខ.ច ហើយបានប្តេជ្ញាចិត្តក្នុងការបន្តចែករំលែកចំណេះដឹងអំពីការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការធ្វើចំណាកស្រុកខុសច្បាប់ ទៅដល់អ្នកដទៃទៀតនៅក្នុងសហគមន៍។ ក្រុមការងាររបស់ គម្រោង ក.ប.ធ.ច.ស.ខ.ច ជឿជាក់ថាសមាជិករបស់ ក.ជ.ខ ដូចជារូបគាត់គឺជាអ្នកនាំពាក្យដ៏សំខាន់នៅក្នុងសហគមន៍ ក្នុងការបង្កើនការយល់ដឹង និងការប្រយុទ្ធប្រឆាំងនឹងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកខុសច្បាប់។

កាលបរិច្ឆេទ៖ ឧសភា ២០១៩